ព្រះរាជាណាចក្រកម្ពុជា

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

នាយកដ្ឋានព័ត៌មាន និងឯកសារ

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនព័ត៌មាន

ដើម្បីសម្រួល និងជំរុញឱ្យមានកំណើនការផ្លាស់ប្តូររវាងប្រជាជន**កម្ពុជា** និងប្រជាជន**ជប៉ុន** រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលជប៉ុនបានព្រមព្រៀងគ្នា ដូចតទៅ:

១- លើកលែងទិដ្ឋាការរយៈពេល **៣០ថ្ងៃ** ដល់អ្នកកាន់**លិខិតឆ្លងដែនការទូត និងផ្លូវការ** កម្ពុជា និងជប៉ុន ។ ការលើកលែងទិដ្ឋាការនេះ នឹងត្រូវប្រកាសក្នុងអំឡុងពេលកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-ជប៉ុន ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៣ ដល់ ១៥ ខែធ្នូ ឆ្នាំ២០១៣ នៅទីក្រុងតូក្យូ ។

២- ផ្តល់**ទិដ្ឋាការចេញ-ចូលច្រើនដងរយៈពេលវែង** ពី **១ ឆ្នាំ** ទៅ **៣ ឆ្នាំ** ដល់អ្នកកាន់**លិខិតឆ្លងដែនធម្មតា** នៃប្រទេសទាំងពីរ ។ ការផ្តល់ទិដ្ឋាការខាងលើនេះ នឹងត្រូវអនុវត្តចាប់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ខាងមុខនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣

អាសយដ្ឋានៈ លេខ ៣ វិថី **សម្តេច ហ៊ុន សែន** សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីមែល : mfaic@mfa.gov.kh